# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០២ អនក្រ

## សេចក្តីសម្រេច
## ស្តីពី
## ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ឆ្នាំ២០០៦ - ២០១០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/០០១ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ១៤៧អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី ១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** ផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ស្តីពីសុខដុមនីយកម្មដើម្បីបង្កើនប្រសិទ្ធភាពនៃជំនួយ សម្រាប់ឆ្នាំ២០០៦ - ២០១០ មានខ្លឹមសារដូចមានភ្ជាប់ជាមួយនឹងសេចក្តីសម្រេចនេះ ។

**ប្រការ ២** : គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចតាមដានការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្មនេះ ដោយសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងជាមួយបណ្តាដៃគូអភិវឌ្ឍន៍ ដោយត្រូវវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការនេះ ក្នុងមួយឆ្នាំម្តងជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣** : គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចធ្វើការពិនិត្យ និងកែសម្រួលសកម្មភាពជាក់ស្តែងនៃផែនការសកម្មភាពនេះ ដើម្បីអោយស្របនឹងស្ថានភាពវិវត្តន៍ ទាំងក្នុងប្រទេស និងទាំងលើឆាកអន្តរជាតិ ដោយត្រូវពិភាក្សា និងឯកភាពជាមួយបណ្តាក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងជាមួយបណ្តាដៃគូអភិវឌ្ឍន៍ ដោយត្រូវរាយការណ៍ជូនគណៈរដ្ឋមន្ត្រីជ្រាបជាព័ត៌មាន ។

**ប្រការ ៤** : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងនិងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ព្រមទាំងក្រុមការងារបច្ចេកទេសចម្រុះ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៥** : សេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ៤ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ